UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for human rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR


# ប្រកាសព័ត៌មាន

*ភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០០៧ : តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ចេញសេចក្តីថ្លែងបំភ្លឺនៅថ្ងៃនេះ ដូចខាងក្រោម :*

លោកតំណាងពិសេស គឺជាអ្នកជំនាញការឯករាជ្យមួយរូប ដែលត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ លោកមានអាណត្តិតាមឃ្លាំមើលការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសនេះ ដើម្បីជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការធានាថា ច្បាប់កម្ពុជា និងបទដ្ឋាននានាដែលរដ្ឋនេះបានទទួលយក ត្រូវបានគោរពយ៉ាងមានប្រសិទ្ធភាព ជំរុញឱ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យសិទ្ធិមនុស្ស និងរាយការណ៍ជារៀងរាល់ឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិដែលទើបបានបង្កើតថ្មី ។

ក្នុងតួនាទីជាតំណាងពិសេស លោកមិនមែនជានិយោជិតរបស់អង្គការសហប្រជាជាតិ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍ដែរ ។ ការងាររបស់លោក គឺបំរើសាធារណជន ហើយមិនយកកំរៃ ។ លោក **យ៉ាសហ៍ ហ្គាយ** គឺជាសាស្ត្រាចារ្យផ្នែកច្បាប់រដ្ឋធម្មនុញ្ញ និងជាអ្នកការពារសិទ្ធិមនុស្សមួយរូបដែលមានបទពិសោធន៍ច្រើន ក្នុងការលើកស្ទួយនីតិរដ្ឋនៅប្រទេសជាច្រើន ។ លោកមិនតំណាងឱ្យប្រទេសកេនយ៉ាទេ ។ លោកតំណាងឱ្យគោលការណ៍សិទ្ធិមនុស្សទាំងឡាយដែលបានតំកល់ក្នុងធម្មនុញ្ញសហប្រជាជាតិ ដែលក្នុងនោះ កម្ពុជាគឺជារដ្ឋសមាជិកមួយ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលសន្ធិសញ្ញាភាគច្រើនត្រូវបានកម្ពុជាផ្តល់សច្ចាប័ន ហើយបានក្លាយជាផ្នែកមួយនៃច្បាប់កម្ពុជា ។

លោកតំណាងពិសេស មិនមានបំណងពិភាក្សាជាមួយរដ្ឋាភិបាលតាមរយៈសារព័ត៌មាននោះទេ ។ លោកបានស្នើសុំជួបប្រជុំជាមុនជាមួយរដ្ឋមន្ត្រីជាច្រើន ក្នុងដំណើរទស្សនកិច្ចនេះ ។ រដ្ឋមន្ត្រីទាំងនោះមិនបានឆ្លើយតបនឹង សំណើនេះ ឬបានបដិសេធមិនជួបលោក ។ ដោយសារមិនមានការប្រជុំទាំងនេះ ទើបលោកថ្លែងជាសាធារណៈអំពីកង្វល់ធំៗ


No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org  Website: http://cambodia.ohchr.org

របស់លោក ដែលលោកមានភារកិច្ចត្រូវបំពេញ ។ កង្វល់ទាំងនេះ នឹងត្រូវបានលើកមកពិភាក្សាជាលំអិត នៅក្នុងរបាយការណ៍លើកក្រោយរបស់លោក ។ លោកសង្ឃឹមថា រដ្ឋាភិបាលនឹងឆ្លើយតបចំពោះខ្លឹមសារនៃការវាយតំលៃរបស់លោក ។ លោកត្រៀមខ្លួន ដើម្បីពិភាក្សាជាលំអិតលើរបាយការណ៍នេះ ហើយនឹងស្តាប់ទស្សនៈរបស់រដ្ឋាភិបាលគ្រប់ពេលវេលា ។ ទ្វាសំរាប់ការពិភាក្សានៅតែបើកចំហជានិច្ចនៅឡើយ ។ ដើម្បីឱ្យមានការពិភាក្សាទៅបាន គេត្រូវតែមានគូសន្ទនា ហើយលោកតំណាងពិសេសនឹងបន្តខិតខំប្រឹងប្រែងក្នុងទិសដៅនេះ ។

ក្នុងការពិនិត្យពិច្ច័យដ៏ស្មោះត្រង់ លើរបាយការណ៍របស់លោកតំណាងពិសេសមុនៗ ចាប់ពីឆ្នាំ១៩៩៣ មកបង្ហាញថា ការរីកចំរើនក្នុងវិស័យនីតិរដ្ឋ និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ គឺជាការរាយការណ៍យ៉ាងត្រឹមត្រូវ ដែលរបាយការណ៍ទាំងនោះតម្រូវឱ្យធ្វើការវាយតំលៃប្រកបដោយភាពយុត្តិធម៌ ។ ទន្ទឹមនឹងនេះ បញ្ហាដែលជាកង្វល់ដូចដែលបានរាយការណ៍នៅក្នុងដំណើរទស្សនកិច្ចកន្លងមក នៅតែបន្តកើតមានជាដដែល ។ បញ្ហាទាំងនេះ គឺជាកង្វល់ដ៏ធ្ងន់ធ្ងរសំរាប់ជីវិតរស់នៅរបស់ប្រជាជនកម្ពុជាជាច្រើននាក់ ។ បញ្ហាទាំងនេះនឹងមិនរលុបបាត់ដោយឯកឯងឡើយ ។ បញ្ហាទាំងនេះទាមទារឱ្យមានការដោះស្រាយ ។ ដូចសុភាសិតខ្មែរមួយពោលថា "ដំរីងាប់មិនអាចយកចង្អេរបាំងបានឡើយ" ។ តួនាទីរបស់លោកតំណាងពិសេស គឺស្វែងយល់អំពីកង្វល់ទាំងនេះ ដើម្បីទាញចំណាប់អារម្មណ៍របស់រដ្ឋាភិបាល ចំពោះបញ្ហាទាំងនេះ និងធ្វើការជាមួយរដ្ឋាភិបាល ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

នៅទីបញ្ចប់ ខ្ញុំសូមធ្វើការបញ្ជាក់បំភ្លឺថា លោកតំណាងពិសេស មិនបានអំពាវនាវឱ្យសហគមន៍អន្តរជាតិកាត់ជំនួយរបស់ខ្លួនដល់កម្ពុជានោះទេ ។ ផ្ទុយទៅវិញ លោកបានជំរុញលើកទឹកចិត្តដល់រដ្ឋជាសមាជិកទាំងអស់ ដែលជាប់កាតព្វកិច្ចក្នុងធម្មនុញ្ញសហប្រជាជាតិ ឱ្យបន្តកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយថែមទៀត ទន្ទឹមនឹងដើរតួនាទីកាន់តែសំខាន់ថែមទៀត ក្នុងការទទួលស្គាល់អំពីការពិតជាក់ស្តែងខាងសិទ្ធិមនុស្សនៅកម្ពុជា គឺជាការទទួលស្គាល់មួយ ដែលលោកតំណាងពិសេស មានអាណត្តិចូលរួមជាវិភាគទាននោះ ។

*ចប់សេចក្តីប្រកាសព័ត៌មាន*